Australian Government
Department of Home Affairs

# កម្មវិធីសម្រួលការមកស្នាក់នៅថ្មីដោយកត្តាមនុស្សធម៌

## ការកែប្រែសេវាកម្មដោយសារកូវីដ-19

ជំនួយក្រោមកម្មវិធីសម្រួលការតាំងទីលំនៅថ្មីដោយកត្តាមនុស្សធម៌ នៅតែមានបន្តជូនអតិថិជនក្នុងអំឡុងពេលមាន កូវីដ-19 រាតត្បាត។ តែរបៀបផ្តល់សេវានេះអាចមានការកែប្រែអាស្រ័យទៅលើឱវាទផ្លូវការរបស់វិស័យសុខាភិបាល។

សូមទាក់ទង **ស្ថាប័នផ្តល់សេវា HSP** របស់លោកអ្នកផ្ទាល់ដើម្បីពិភាក្សារបៀបចាត់ចែងថ្មី។

ស្វែងយល់អំពី **កូវីដ-19 និងរោគសញ្ញារបស់វា**។

## ទិដ្ឋភាពរួម

កម្មវិធីសម្រួលការតាំងទីលំនៅដោយកត្តាមនុស្សធម៌ (Humanitarian Settlement Program (HSP))

ផ្តល់ការគាំពារដល់ជនចូលមករស់នៅថ្មីដោយសារកត្តាមនុស្សធម៌ ក្នុងការកសាងជំនាញនិងចំណេះដែលពួកគេត្រូវការដើម្បីក្លាយទៅជាមនុស្សដែលអាចរស់ដោយខ្លួនឯងបាននិងទៅជាសមាជិកសកម្មក្នុងសង្គមអូស្ត្រាលី។

កម្មវិធី HSP នេះផ្តល់ជូនដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈស្ថាប័នផ្តល់សេវាដែលមានចុះកិច្ចសន្យាទូទាំងប្រទេសអូស្ត្រាលី។ ការចូលរួមក្នុងកម្មវិធី HSP នេះគឺធ្វើឡើងដោយស្ម័គ្រចិត្ត ហើយសេវាកម្មទាំងឡាយនោះផ្តល់ជូនអតិថិជនអាស្រ័យតាមសេចក្តីត្រូវការរបស់ករណីនីមួយៗ។

អ្នកផ្តល់សេវា HSP ជួយអតិថិជនឲ្យទទួលបានលទ្ធផលក្នុងវិស័យអាទិភាពខាងក្រោមនេះ ដែលជាមូលដ្ឋាននៃការសម្រួលការតាំងទីលំនៅដែលប្រកបដោយជោគជ័យ ៖

- ការងារធ្វើ
- សិក្សាធិការនិងការហ្វឹកហាត់បណ្តុះបណ្តាល
- សេវាភាសា
- លំនៅដ្ឋាន
- ការចាត់ចែងលុយកាក់
- សុខភាពផ្លូវកាយនិងផ្លូវចិត្ត ព្រមទាំងសុខុមាលភាព
- ការចូលរួមក្នុងសកម្មភាពសង្គម និងចងក្រងបណ្តាញសង្គម
- ដំណើរការរបស់គ្រួសារ និងជំនួយផ្គត់ផ្គង់ដោយសង្គម
- វិស័យយុត្តិធម៌

កម្មវិធី HSP រៀបចំឡើងដើម្បីធ្វើសហការជាមួយបណ្តាសេវាផ្តល់ជំនួយផ្នែកតាំងទីលំនៅថ្មី និងសេវាកម្មចម្បងៗដទៃទៀត។ កម្មវិធីនេះសំដៅខ្ពស់ទៅលើការជួយអតិថិជនក្នុងការរៀនភាសាអង់គ្លេស និងទទួលបានការសិក្សានិងជំនាញការងារចាំបាច់ ដោយទទួលស្គាល់ថា លទ្ធផលវិជ្ជមានពីវិស័យទាំងនេះជួយជំរុញឲ្យជនមកតាំងទីលំនៅថ្មីដោយសារកត្តាមនុស្សធម៌ ឈានទៅរកការចូលរួមក្នុងសង្គមអូស្ត្រាលីបានល្អប្រសើរ។

ការិយាល័យនិងលេខទំនាក់ទំនងរបស់ស្ថាប័នផ្តល់សេវា HSP មាននៅ ទីនេះ។

## ភាពមានសិទ្ធិ

នៅពេលបុគ្គលម្នាក់ត្រូវបានផ្តល់ទិដ្ឋាការមួយក្នុងចំណោមទិដ្ឋាការខាងក្រោមនេះដើម្បីឲ្យមកតាំងទីលំនៅថ្មីក្នុងប្រទេស អូស្ត្រាលី ក្រសួងមហាផ្ទៃបញ្ជូនឈ្មោះបុគ្គលនោះទៅស្ថាប័នផ្តល់សេវា HSP ដើម្បីទទួលបានជំនួយក្រោមកម្មវិធី HSP នៅពេលគេមកដល់ប្រទេសអូស្ត្រាលី។

- ទិដ្ឋាការជនភៀសខ្លួន (អនុប្រភេទលេខ 200, 201, 203 និង 204) ហើយនិង
- ទិដ្ឋាការមនុស្សធម៌ពិសេសពិភពលោក (អនុប្រភេទលេខ 202) (មិនរាប់បញ្ចូលឡើយ អ្នកចូលរួមក្នុងកម្មវិធីគាំពារដោយសង្គម)។

## សេវាកម្មទាំងឡាយ

ប្រធានកាន់សំណុំឯកសារនៃ HSP ធ្វើការជាមួយអតិថិជនក្នុងការកសាងផែនការសម្រាប់ម្នាក់ៗ ហើយនិងផ្តល់សេវានានាមួយចំនួនដែលតម្រូវទៅតាមសេចក្តីត្រូវការដែលបានពិនិត្យឃើញ។

សេវាទាំងនោះមានរាប់បញ្ចូលជំនួយគាំពារដំបូងដូចជា ៖

- ការទទួលនៅព្រលានយន្តហោះ
- កន្លែងស្នាក់នៅពេលមកដល់ភ្លាម និងការណែនាំឲ្យយល់អំពីលំនៅដ្ឋាន
- ការផ្តល់អាហារដំបូង និងកញ្ចប់គ្រឿងបរិក្ខារចាំបាច់
- ការជួយចុះឈ្មោះនៅសិនថឺលីង(Centrelink) មេឌិឃែរ( Medicare) និងធនាគារ
- ការដោះស្រាយសេចក្តីត្រូវការបន្ទាន់ក្នុងវិស័យសុខភាព
- សេចក្តីណែនាំឲ្យដឹងថាត្រូវធ្វើអ្វីក្នុងករណីមានអាសន្ន ហើយនិងរបៀបរកសេវាបកប្រែ
- ការណែនាំឲ្យយល់អំពីសេវាកម្មនានានៅតាមមូលដ្ឋាន

សេវាកម្មដទៃទៀតសម្រាប់ជួយឲ្យអតិថិជនទទួលបានលទ្ធផលល្អនៃការមកតាំងទីលំនៅថ្មី រួមមាន ៖

- ការផ្តល់កម្មវិធីណែនាំក្នុងប្រទេស ដែលបណ្តុះការយល់ដឹងរបស់អតិថិជនអំពីគុណតម្លៃ និងរបៀបរបបរស់នៅក្នុងប្រទេសអូស្ត្រាលី
- ការជួយរកផ្ទះស្នាក់នៅសម្រាប់ពេលយូរអង្វែង។
- ការជួយរកសេវាចម្បងៗ រួមទាំងសេវាសុខាភិបាលនិងសេវាគាំពារគ្រួសារ
- ការផ្សារភ្ជាប់ជាមួយក្រុមនិងសកម្មភាពរបស់សហគមន៍នៅមូលដ្ឋាន
- ការជួយចុះឈ្មោះក្នុងកម្មវិធីរៀនភាសាអង់គ្លេសសម្រាប់ជនពេញវ័យ (AMEP) ការជូនទៅរៀន។
- ការជួយចុះឈ្មោះសិក្សានិងបណ្តុះបណ្តាលចំណេះ ហើយនិងទទួលស្គាល់ជំនាញនិងសញ្ញាបត្រដែលគេមានមុនមកដល់
- ជំនួយពាក់ព័ន្ធនឹងសេវារកការងារធ្វើ អនុវត្តយុទ្ធសាស្ត្រនៃការធ្វើការ ហើយនិងរកសេវាសម្រាប់ជួយបង្កើតអាជីវកម្ម។

ស្ថាប័នផ្តល់សេវា HSP ក៏អាចសម្រួលការដាក់ពាក្យសុំសេវាបកប្រែដោយឥតគិតថ្លៃ (FTS) ចំពោះអតិថិជនដែលមានសិទ្ធទទួលសេវា FTS នេះ ហើយមិនអាចដាក់ពាក្យសុំតាមអនឡាញបាន។

ការចាកចេញពីកម្មវិធី HSP
គឺអាស្រ័យលើលទ្ធផលដែលធ្វើបានក្នុងកម្មវិធីមកតាំងទីលំនៅថ្មីដែលគេបានពិនិត្យឃើញនិងចារនៅក្នុងឯកសារករណីផែនការរបស់ពួកគេ។ សម្រាប់អតិថិជនភាគច្រើន ការទទួលបានលទ្ធផលទាំងនោះ
គឺសម្រេចបាននៅពេលគេមកដល់ប្រទេសអូស្រ្តាលីបាន៦ ទៅ ១៨ ខែ។